**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងធម្មការនិងសាសនា**
លេខៈ ៦៨/២៤ ក.ធ.ស/ប្រ.ក

# ប្រកាស
## ស្តីពី
## ការរៀបចំនិងការប្រព្រឹត្តទៅ នៃការប្រឡងវិញ្ញាបនបត្រពុទ្ធិកបឋមសិក្សា

## រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការនិងសាសនា
- បានឃើញអនុក្រឹត្យលេខ ១៥៤ អនក្រ.បក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់ក្រសួងធម្មការនិងសាសនា
- បានឃើញប្រកាសលេខ ១៩/១២ ក.ធ.ស/ប្រក ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការប្រើប្រាស់សៀវភៅកម្មវិធីពុទ្ធិកបឋមសិក្សា
- យោងលិខិតលេខ ១៤៣/២៤ អ.ព.ស.ជ ចុះថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២៤ ស្តីពីផែនការប្រឡងសម្រាប់ឆ្នាំសិក្សា២០២៤-២០២៥

## សម្រេច

**ប្រការ១ .-**

មណ្ឌលប្រឡងវិញ្ញាបនបត្រពុទ្ធិកបឋមសិក្សា ត្រូវកំណត់ដោយក្រសួងធម្មការនិងសាសនារៀងរាល់ឆ្នាំសិក្សា។

**ប្រការ២ .-**

រាជធានី ខេត្ត ដែលបានបង្កើតសាលាពុទ្ធិកបឋមសិក្សា ហើយដែលមានសមណសិស្ស សិស្សរៀនចប់កម្មវិធីពុទ្ធិកបឋមសិក្សា៣ឆ្នាំ មានចំនួន១០០រូបឡើងទៅ អាចរៀបចំមណ្ឌលប្រឡងវិញ្ញាបនបត្រពុទ្ធិកបឋមសិក្សាបាន។

**ប្រការ៣ .-**

ប្រធានមន្ទីរធម្មការនិងសាសនារាជធានី ខេត្ត ដែលកំណត់ឱ្យបើកមណ្ឌលប្រឡង គឺមានភារកិច្ចរៀបចំបន្ទប់ប្រឡង និងសម្ភារៈចាំបាច់សម្រាប់ការប្រព្រឹត្តទៅ នៃការប្រឡងឱ្យបានរួចរាល់មុនបើក សម័យប្រឡង។

**ប្រការ៤ .-**

ដើម្បីពង្រឹងការងារពុទ្ធិកបឋមសិក្សាឱ្យមានការអភិវឌ្ឍ ក្រសួងធម្មការនិងសាសនាបានចាត់តាំងឱ្យមានមណ្ឌលប្រឡងនិងមណ្ឌលកំណែ ។ ៸



អាសយដ្ឋានៈ វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរសព្ទៈ (៨៥៥-២៣) ៧២២ ៦៥៥
អ៊ីមែលៈ mocargovkh@gmail.com
គេហទំព័រៈ www.mocar.gov.kh

**ប្រការ៥** ..

មណ្ឌលប្រឡងនីមួយៗ ត្រូវមានប្រធាន អនុប្រធាន និងសមាជិកមេប្រយោគមួយចំនួនតាមការចាំបាច់នៃមណ្ឌលប្រឡង ។

**ប្រការ៦** ..

សមាសភាពគណៈកម្មការមណ្ឌលប្រឡងនិងមណ្ឌលកំណែ ត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា តាមសេចក្ដីស្នើសុំរបស់មន្ទីរធម្មការនិងសាសនារាជធានី ខេត្ត និងសេចក្ដីស្នើរបស់អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ។

**ប្រការ៧** ..

បន្ទប់ប្រឡងនីមួយៗត្រូវដាក់បេក្ខសមណៈ បេក្ខជនត្រឹម២៥រូប (ម្ភៃប្រាំរូប)។ បើមានបេក្ខសមណៈ បេក្ខជននៅសល់៥រូប (ប្រាំរូប) ឡើងទៅត្រូវដាក់ក្នុងបន្ទប់មួយដោយឡែក។

**ប្រការ៨** ..

ប្រធានមណ្ឌលនៃមណ្ឌលប្រឡងនីមួយៗជាអ្នកទទួលខុសត្រូវរួម ក្នុងដំណើរការប្រព្រឹត្តទៅនៃដំណើរការវិញ្ញាសាសរសេរ ទាំងផ្នែករដ្ឋបាលនិងផ្នែកបច្ចេកទេស ចំពោះក្រសួងធម្មការនិងសាសនា។

**ប្រការ៩** ..

ប្រធានមណ្ឌល ត្រូវសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចនានា ក្នុងរាជធានី ខេត្ត នៃមណ្ឌលប្រឡង ក្នុងករណីចាំបាច់ ដើម្បីរក្សារបៀបរៀបរយក្នុងពេលប្រឡង។

**ប្រការ១០** ..

មណ្ឌលប្រឡងណាមួយ ដែលមិនមានភាពប្រក្រតីតាមលក្ខណៈនៃការប្រឡង ប្រធានឬអនុប្រធានមណ្ឌលនោះត្រូវរាយការណ៍ជាបន្ទាន់ មកគណៈមេប្រយោគទូទាំងប្រទេសនិងអាជ្ញាធរដែនដី ដើម្បីដោះស្រាយឬសុំការសម្រេចពីក្រសួងធម្មការនិងសាសនា។

**ប្រការ១១** ..

ប្រធានមណ្ឌលប្រឡងនីមួយៗ ត្រូវបែងចែកភារកិច្ចដល់អនុប្រធាននិងសមាជិកមេប្រយោគឱ្យទទួលខុសត្រូវរៀងៗខ្លួន។ ភារកិច្ចគណៈកម្មការ អនុគណៈកម្មការ សមាជិកមេប្រយោគ នឹងមានចែងក្នុងសេចក្ដីណែនាំ អំពីភារកិច្ចនៃគណៈមេប្រយោគ។

**ប្រការ១២** ..

អនុញ្ញាតឱ្យចុះឈ្មោះប្រឡងបាន សមណសិស្ស សិស្ស ថ្នាក់ឆ្នាំទី៣ នៃសាលាពុទ្ធិកបឋមសិក្សា ដែលបានរៀនចប់កម្មវិធីសិក្សាថ្នាក់ឆ្នាំទី៣ និងគោរពឱ្យបានត្រឹមត្រូវនូវបទបញ្ជាផ្ទៃក្នុង សម្រាប់សាលាពុទ្ធិកបឋមសិក្សា។

**ប្រការ១៣** ..

អាចចុះឈ្មោះប្រឡងវិញ្ញាបនបត្រពុទ្ធិកបឋមសិក្សា ជាបេក្ខសមណៈ បេក្ខជនសេរីនបាន ចំពោះតែអតីតបេក្ខសមណៈ បេក្ខជនដែលប្រឡងធ្លាក់វិញ្ញាបនបត្រពុទ្ធិកបឋមសិក្សា។

**ប្រការ ១៤** ..

សំណុំលិខិតដែលបេក្ខសមណៈ បេក្ខជនត្រូវភ្ជាប់មកជាមួយនូវ៖

| | |
|---|---|
| - ពាក្យសុំចុះឈ្មោះប្រឡងមានបិទតែម | ចំនួន១ ច្បាប់ |
| - ជីវប្រវត្តិសង្ខេប មានបិទរូបថត (៤ x ៦) | ចំនួន១ ច្បាប់ |
| - លិខិតបញ្ជាក់ការសិក្សា | ចំនួន១ ច្បាប់ |
| - សលាកបត្រឯកត្តជនទំហំ (១៥ x ២១) មានបិទរូបថត(៤x៦) | ចំនួន២ ច្បាប់ |
| - សំបុត្រកំណើត ( ថតចម្លង ) | ចំនួន១ ច្បាប់ |
| - រូបថតទំហំ ៤ x ៦ ថតចំពីមុខ (ឃ្មុំ) | ចំនួន៤ សន្លឹក។ |

**ប្រការ១៥..**

ពាក្យសុំចុះឈ្មោះប្រឡង នឹងត្រូវប្រមូលផ្ដុំទៅតាមមន្ទីរធម្មការនិងសាសនាខេត្ត ដើម្បីធ្វើការបែងចែក នាមត្រកូលបេក្ខសមណៈ បេក្ខជនតាមលំដាប់អក្ខរក្រម (លំដាប់ព្យញ្ជនៈនិងស្រៈ) នៅក្នុងបន្ទប់ប្រឡង នីមួយៗ។ ចំពោះរាជធានីភ្នំពេញ ឋិតនៅក្រោមការចាត់ចែងនិងទទួលខុសត្រូវផ្ទាល់របស់អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ។ មន្ទីរធម្មការនិងសាសនាខេត្ត ត្រូវធ្វើបញ្ជីរាយនាមបេក្ខសមណៈ បេក្ខជនផ្ញើមកក្រសួងធម្មការនិងសាសនា តាមរយៈអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិដើម្បីពិនិត្យសម្រេចលើបេក្ខភាព។

**ប្រការ១៦..**

វិញ្ញាសា ថិរវេលា ពិន្ទុ និងមេគុណនៃការប្រឡងវិញ្ញាបនបត្រពុទ្ធិកបឋមសិក្សានិងត្រូវបានកំណត់ ដូចខាងក្រោម៖

| ល.រ. | មុខវិជ្ជាប្រឡង | រយៈពេល | ពិន្ទុ | ផ្សេងៗ |
|---|---|---|---|---|
| ០១ | បាលីប្រែលោតប្រយោគ និងវេយ្យាករណ៍ | ១២០ នាទី | ៦០ | |
| ០២ | តែងសេចក្ដី | ១២០ នាទី | ៤០ | |
| ០៣ | ប្រវត្តិ-ភូមិ-វិទ្យាសាស្ត្រអនុវត្តន៍ | ១២០ នាទី | ២០ | |
| ០៤ | ពុទ្ធវិន័យ ពុទ្ធប្បវត្តិ និងពុទ្ធសាសនា | ១២០ នាទី | ៦០ | |
| ០៥ | សរសេរតាមអាន | ៩០ នាទី | ៤០ | |
| ០៦ | គណិតវិទ្យា | ១២០ នាទី | ៤០ | |
| | សរុប | | ២៦០ | |
| | ពិន្ទុប្រចាំឆ្នាំ (ឆមាសទី១ + ឆមាសទី២) | | ១០០% | នៃពិន្ទុសរុប |
| | ពិន្ទុសរុប | | ៣៦០ | |
| | ពិន្ទុជាប់ | | ១៨០ | |

វិញ្ញាសានីមួយៗ ត្រូវបានពិន្ទុសូន្យ ចំពោះបេក្ខសមណៈ បេក្ខជន អវត្តមាន ឬបេក្ខសមណៈ បេក្ខជន មិនបានប្រគល់សន្លឹកកិច្ចការដល់គណៈមេប្រយោគ។

**ប្រការ១៧..**

ប្រធានវិញ្ញាសាប្រឡងត្រូវយកតាមកម្មវិធីសិក្សាថ្នាក់ឆ្នាំទី៣ នៃពុទ្ធិកបឋមសិក្សា (បាលីរង) កម្រិតពុទ្ធិកបឋមសិក្សានៃអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ ។

**ប្រការ១៨..**

ប្រធានវិញ្ញាសាទាំងឡាយ ត្រូវជ្រើសរើសឬតាក់តែងដោយអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិនៃក្រសួងធម្មការនិងសាសនា។

**ប្រការ១៩..**

ប្រធានវិញ្ញាសាដែលបានប្រមូលរួចហើយ ត្រូវដាក់ក្នុងស្រោមបិទជិតនិងប្រថាប់ត្រាហើយ ត្រូវបញ្ជូនទៅគណៈ-ប្រតិភូចុះតាមមណ្ឌលប្រឡង និងប្រគល់ជូនអភិបាលខេត្តឬតំណាង។

**ប្រការ២០..**

ការប្រគល់ឱ្យនិងការទទួលយកនូវប្រធានវិញ្ញាសាប្រឡង ត្រូវមានការទទួលខុសត្រូវទាំងសងខាង ដោយមានកំណត់ហេតុជាផ្លូវការផង។

**ប្រការ២១..**

វិញ្ញាសានីមួយៗ ត្រូវមានចំនួនសន្លឹកវិញ្ញាសាស្មើនឹងចំនួនបន្ទប់បើខ្វះត្រូវចម្លងបន្ថែមបង្គ្រប់ភ្លាម។

**ប្រការ២២..**

ដំណើរការកំណែ ត្រូវប្រព្រឹត្តទៅតាមមណ្ឌលកំណែនីមួយៗ។ ៘

**ប្រការ២៣ ..**

ប្រធាន អនុប្រធានគណៈមេប្រយោគខេត្ត មានសិទ្ធិចុះលេខសម្ងាត់ ចុះហត្ថលេខាលើតារាងពិន្ទុ ចំពោះបញ្ជីជាប់ធ្លាក់សម្រាប់បិទផ្សាយ ត្រូវចេញដោយសម្តេចព្រះអគ្គាធិការ និងរដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា។

**ប្រការ២៤ ..**

បន្ទាប់ពីបញ្ចប់ដំណើរការវិញ្ញាសាសរសេរ ប្រធានមណ្ឌលប្រឡងនីមួយៗ ត្រូវប្រមូលកិច្ចការ បេក្ខសមណៈ បេក្ខជននិងកំណត់ហេតុដំណើរការវិញ្ញាសាសរសេរមកប្រគល់ឱ្យប្រធានមណ្ឌលកំណែភ្លាម។

**ប្រការ២៥ ..**

ប្រធាន អនុប្រធានមណ្ឌលនីមួយៗ ត្រូវចូលរួមបន្តការងារនៅមណ្ឌលកំណែនិងអនុវត្តភារកិច្ចតាមការចាត់តាំងរបស់ប្រធានមណ្ឌលកំណែ។ មណ្ឌលកំណែនីមួយៗ ត្រូវបែងចែកជាក្រុមតាមមុខវិជ្ជា។

**ប្រការ២៦ ..**

ប្រធាននិងអនុប្រធានកំណែតាមមុខវិជ្ជានីមួយៗ ត្រូវជ្រើសរើសតាមការចាត់តាំងរបស់ប្រធានគណៈ មេប្រយោគ។

**ប្រការ២៧ ..**

កិច្ចការបេក្ខសមណៈ បេក្ខជននីមួយៗ ត្រូវកែដោយសមាជិកកំណែពីរនាក់ជាដាច់ខាត តាមអត្រាកំណែដែលគណៈមេប្រយោគបានសម្រេចនិងចុះហត្ថលេខាទទួលខុសត្រូវផង ។

**ប្រការ២៨ ..**

បេក្ខសមណៈ បេក្ខជនទាំងឡាយណា ដែលបានពិន្ទុប្រឡងចាប់ពី១៥០ ឡើងទៅ នឹងត្រូវប្រកាសថា បានប្រឡងជាប់វិញ្ញាបនបត្រពុទ្ធិកបឋមសិក្សា។ ក្នុងករណីចាំបាច់អាចធ្វើសម្រង់ឱ្យជាប់បន្ថែម ក្រោយពីមានការយល់ព្រម ពីអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិនិងតាមសំណើរបស់ប្រធានគណៈកម្មការកំណែ គណៈកម្មការត្រួតពិនិត្យនិងផ្ទៀងផ្ទាត់លទ្ធផល ។

**ប្រការ២៩ ..**

ក្រោយពីបូកពិន្ទុបេក្ខសមណៈបេក្ខជនកំណត់ប្រឡងជាប់ធ្លាក់តាមមណ្ឌលប្រឡងនីមួយៗរួចគណៈ មេប្រយោគត្រូវប្រជុំធ្វើកំណត់ហេតុប្រឡងនិងបញ្ជីឈ្មោះជាប់ ធ្លាក់(ដោយកំណត់និទ្ទេសដូចខាងក្រោម) ផ្ញើមកអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិនៃក្រសួងធម្មការនិងសាសនា នឹងបិទផ្សាយ តាមមណ្ឌលប្រឡងនីមួយៗជាបន្ទាន់ ។

| | | | |
|---|---|---|---|
| F: Weak | ធ្លាក់ | = ពិន្ទុសរុប x 0.១ | = ១0% - ៤៩% |
| E: Limited Achievment | មធ្យម | = ពិន្ទុសរុប x 0.៥ | = ៥0% - ៥៩% |
| D: Satisfactory | ល្អបង្គួរ | = ពិន្ទុសរុប x 0.៦ | = ៦0% - ៦៩% |
| C: Good | ល្អ | = ពិន្ទុសរុប x 0.៧ | = ៧0% - ៧៩% |
| B: Very Good | ល្អណាស់ | = ពិន្ទុសរុប x 0.៨ | = ៨0% - ៨៩% |
| A: Excellent | ល្អប្រសើរ | = ពិន្ទុសរុប x 0.៩ | = ៩0% - ១00% |

**ប្រការ៣០ ..**

គណៈកម្មការគ្រប់ផ្នែកនៃមណ្ឌលប្រឡងនិងមណ្ឌលកំណែនីមួយៗ ត្រូវរក្សាការសម្ងាត់ក្នុងកិច្ចការប្រឡងឱ្យបានល្អប្រសើរ។ ន

**ប្រការ៣១ ..**

បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីនេះ នឹងត្រូវទុកជានិរាករណ៍។

**ប្រការ៣២ ..**

នាយកខុទ្ទកាល័យ ព្រះអគ្គាធិការនៃអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការសាសនា និងអង្គភាពក្រោមឱវាទក្រសួងធម្មការនិងសាសនាត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ៩រោច ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ២០២៤

**រដ្ឋមន្ត្រី**

ចាយ_បុរិន

**កន្លែងទទួល៖**

- សម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ
- គណៈសង្ឃនាយកទាំងពីរគណៈ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងអប់រំ យុវជន និងកីឡា
- រដ្ឋបាលរាជធានី ខេត្ត
- អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ
- មន្ទីរធម្មការនិងសាសនារាជធានី ខេត្ត
- គ្រប់អង្គភាពពាក់ព័ន្ធ
- ដូចប្រការ៣២
- ឯកសារ កាលប្បវត្តិ